**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០៨-០៦៣ ប្រ.ក

## ប្រកាស
## ស្តីពី
## ការតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- បានឃើញបទប្បញ្ញត្តិលេខធ៧៩៧-០២បប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីវិសោធនកម្មលើលក្ខខណ្ឌនៃការតម្កល់ប្រាក់បំរុងកាតព្វកិច្ច លើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ដោយស្ថាប័ន រូបិយវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨

## ស ម្រេ ច

### ប្រការ ១.-

ធនាគារពាណិជ្ជ ត្រូវតម្កល់ប្រាក់បំរុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចី ជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា ស្មើនឹងប្រាំបីភាគរយ(៨%)ចំពោះប្រាក់រៀល និងដប់ប្រាំមួយភាគរយ(១៦%)ចំពោះ ប្រាក់រូបិយប័ណ្ណ។

### ប្រការ ២.-

ធនាគារជាតិនៃកម្ពុជានឹងផ្តល់កំរៃការប្រាក់ ដូចខាងក្រោម :

- ចំពោះប្រាក់បំរុងកាតព្វកិច្ចជាប្រាក់រៀលចំនួនប្រាំបីភាគរយ (៨%) មានអត្រាការប្រាក់សូន្យភាគរយ (0%)

- ចំពោះប្រាក់បំរុងកាតព្វកិច្ចជាប្រាក់រូបិយប័ណ្ណចំនួនដប់ប្រាំមួយភាគរយ (១៦%) ក្នុងនោះ ប្រាំបីភាគរយ (៨%)មានអត្រាការប្រាក់សូន្យភាគរយ (0%) និងប្រាំបីភាគរយ (៨%) បន្ថែមទៀត ផ្តល់អត្រាការប្រាក់បីភាគបួន (៣/៤) ស្មើនឹង 0,៧៥នៃអត្រា SIBOR គិតលើមូលដ្ឋានមួយខែ។

### ប្រការ ៣.-

ធនាគារពាណិជ្ជដែលទទួលរងឱនភាពប្រាក់បំរុងកាតព្វកិច្ច ត្រូវទទួលរងការផាកពិន័យ ស្មើនឹងសូន្យក្បៀសមួយភាគរយ (0,១%) នៃប្រាក់ដែលទទួលរងឱនភាព ។ ធនាគារពាណិជ្ជណាដែលមិនគោរពតាមប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុង មាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៤.-**

បទប្បញ្ញត្តិលេខធ៧៩៧-០២បប ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីវិសោធនកម្មលើលក្ខខណ្ឌនៃការតម្កល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់សុំខ្ចីចងការផ្សេងៗ ដោយស្ថាប័នរូបិយវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីរយៈពេលមូលដ្ឋានពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ តទៅ អនុលោមតាមសារាចរណែនាំលេខធ៧-០៧-០១ សរណន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីរយៈពេលមូលដ្ឋាន និងរយៈពេលដែលត្រូវតម្កល់និងថ្ងៃរាយការណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"